ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែមករា ឆ្នាំ២០២៤

នៅក្នុងខែមករា ឆ្នាំ២០២៤នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

**១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

១.១-សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

១.១.១-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន០១លើក។

១.១.២-សកម្មភាពចុះមូលដ្ឋាន

-បានអញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខ សមាជិក សមាជិកាក្រុមប្រឹក្សាសង្កាត់ ទូទាំងខណ្ឌទួលគោក ខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌពោធិ៍សែនជ័យ ខណ្ឌច្បារអំពៅ និងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

-បានអញ្ជើញសាកសួរសុខទុក្ខលោកតា **ជាវ ឡាវ** មានជំងឺបាក់ត្រគៀកចង្កេះ ដែលកំពុងស្នាក់នៅក្នុងវត្តសុវណ្ណគិរី(ហៅវត្តជើងឆ្នុក) ស្ថិតក្នុងភូមិជើងឆ្នុក ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម។

១.១.៣-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញចូលរួមពិធីពិសាភោជនាហារសាមគ្គី នៅស្ថានអគ្គរដ្ឋទូតនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំព្រះរាជាណាចក្រកម្ពុជា

-បានអញ្ជើញប្រារព្ធពិធីបង្សុកូលបុណ្យគម្រប់៦ឆ្នាំ ឧទ្ទិសកុសលដល់ដួងវិញ្ញាណក្ខន្ធលោកតា **គង់ ខាត់** ដែលត្រូវជាឪពុកក្មេករបស់សម្តេច តាមទំនៀមទម្លាប់ខ្មែរ និងតាមគន្លងប្រពៃណីព្រះពុទ្ធសាសនា នៅវត្តសុវណ្ណគិរី(ហៅវត្តជើងឆ្នុក) ស្ថិតក្នុងភូមិជើងឆ្នុក ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម

-បានអញ្ជើញចូលរួមពិធីបុណ្យសពឧបាសិកា **ឡុង សាវ៉ាត** ត្រូវជាម្តាយបង្កើត ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល នៅវត្តលង្កាព្រះកុសុមារាម រាជធានីភ្នំពេញ។



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

១.១.៤-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន០២ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន១០ច្បាប់។

**១.២-ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា អនុប្រធានទី១ព្រឹទ្ធសភា**

១.២.១-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន ០១លើក។

១.២.២-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន០៧ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន៣៤ច្បាប់។

**១.៣-ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា**

១.៣.១-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន ០១លើក។

១.៣.២-សកម្មភាពចុះមូលដ្ឋាន

-បានចាត់ឱ្យក្រុមការងារដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជា-ពលរដ្ឋដោយឥតគិតថ្លៃ នៅក្រុងតាខ្មៅ ខេត្តកណ្តាល។

១.៣.៣-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញទស្សនាការហាត់សមរបាំ ដើម្បីត្រៀមសម្តែងក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៥ នៃទិវាជ័យជម្នះ៧មករា នៅនាយកដ្ឋានសិល្បៈទស្សនីយភាពនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រាជធានីភ្នំពេញ

-បានអញ្ជើញក្រុងពាលីសុំសេចក្តីសុខ និងចូលរួមជាគណៈអធិបតីក្នុងពិធីខួបអនុស្សាវរីយ៍លើកទី៤៥ នៃទិវាជ័យជម្នះ៧មករា នៅទីធ្លាមុខសាលមហោស្រពកោះពេជ្រ រាជធានីភ្នំពេញ

-បានអញ្ជើញរៀបចំកម្មវិធីជប់លៀងជូនលោកស្រី **គូរីន ដុបាស (កាញ៉េ)** នាយិកាសមាគមបេសកកម្មមនុស្សធម៌ប្រចាំប្រទេសបារាំង និងសហការី ក្នុងឱកាសដែលលោកស្រី និងសហការីអញ្ជើញមកទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា

-បានអញ្ជើញជាអធិបតីក្នុងពិធីផ្តល់ភ្លើងបូជាសពឧបាសក **ជិន សារ៉ន** នៅវត្តញាណរង្សីស្ថិតនៅសង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

១.៣.៤-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន០៩ច្បាប់ និងជ្រាបជា

ព័ត៌មាន ចំនួន៤៥ច្បាប់។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា**

ព្រឹទ្ធសភាបានបើកកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន០១លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដើម្បីពិនិត្យ និងសម្រេច៖

១-របាយការណ៍ទូទាត់ថវិការបស់ព្រឹទ្ធសភា ឆ្នាំ២០២៣

២-គោលការណ៍បែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភា ឆ្នាំ២០២៤។

**៣-គណៈកម្មការនានារបស់ព្រឹទ្ធសភា**

សមាជិក សមាជិកាព្រឹទ្ធសភាបានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

**៣.១-មុខងារតាមដានការអនុវត្តច្បាប់**

-បានអញ្ជើញចុះបំពេញបេសកកម្មសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ និងពិនិត្យស្ថានភាពចេញ-ចូលរបស់ភ្ញៀវជាតិ-អន្តរជាតិនៅច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ នៅក្រុងសំរោង និងនៅច្រកទ្វារព្រំដែនអន្តរជាតិជាំ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

**៣.២-មុខងារតំណាង**

-បានទទួលពាក្យបណ្តឹង ចំនួន០១ករណី បានបញ្ជូនពាក្យបណ្តឹងទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ ចំនួន០២ករណី កំពុងពិនិត្យសិក្សា ចំនួន០៥ករណី តម្កល់ទុកមិនចាត់ការ ចំនួន០២ករណី ឆ្លើយតបទៅម្ចាស់បណ្តឹង ចំនួន០៣ករណី បានទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន០១ករណី

-ថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីមីទ្ទិញអបអរសាទរខួបលើកទី៤៥ នៃទិវាជ័យជម្នះ ៧មករា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅទីធ្លាមុខសាលមហោស្រពកោះពេជ្រ រាជធានីភ្នំពេញ

-បានអញ្ជើញជាកិត្តិយសក្នុងពិធីបើកឆ្នាំនៃការផ្លាស់ប្តូរប្រជាជន និងប្រជាជនកម្ពុជា-ចិន ២០២៤ នៅខេត្តសៀមរាប

-បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

-បានអញ្ជើញជាវាគ្មិនក្នុងកម្មវិធីបើកសន្និសីទស្តីពី ចំណីសត្វនៅកម្ពុជារបស់សមាគមសណ្តែកសៀងសហរដ្ឋអាមេរិក សមាគមវីស (WISHH) និងសមាគមណ័រខ្ទែន សយ (NORTHERN SOY) ដើម្បីចែករំលែកចំណេះដឹង បទពិសោធន៍ បច្ចេកទេស ក្នុងការផលិតចំណី និងចិញ្ចឹមសត្វដើម្បី

ផ្គត់ផ្គង់ដល់បណ្ដាញអាជីវកម្ម និងទីផ្សារនៅកម្ពុជា នៅសណ្ឋាគារ សូហ្វីតែលភ្នំពេញ រាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន០៧លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រួមមានៈ ពិធីប្រារព្ធខួបលើកទី២៥ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា និងការអនុវត្តប្រកបដោយជោគជ័យនយោបាយឈ្នះ ឈ្នះ និងខួប៥ឆ្នាំ នៃការកសាងវិមានឈ្នះ ឈ្នះ, ពិធីអបអរសាទរខួបលើកទី២៥ ថ្ងៃបង្កើតបញ្ជាការដ្ឋានកងទ័ពជើងគោក ២៤ មករា ១៩៩៩- ២៤ មករា ២០២៤, ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្ពាន សម្ដេចតេជោ **ហ៊ុន សែន** កោះយ៉ និងពិធីសំណេះសំណាលជាមួយកម្មករ និយោជិត, ពិធីសំណេះសំណាលជាមួយសិស្សនិទ្ទេស A នៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងការប្រឡងសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវកម្រិត៣, ពិធីប្រកាសផ្សព្វ-ផ្សាយរបាយការណ៍ថ្នាក់ជាតិស្ដីពី លទ្ធផលចុងក្រោយ នៃជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២២, និងពិធីបិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទូទាំងប្រទេសប្រចាំឆ្នាំ២០២៣ និងទិសដៅអនុវត្តឆ្នាំ២០២៤ នៅរាជធានីភ្នំពេញ និងខេត្តកោះកុង

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាល សាក-សួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន យុវជន-យុវនារី ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្ដិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្ដាប់ធ្នាប់ ការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានី និងតាមបណ្ដាខេត្ត ក្រុងនានា ចំនួន១៦០លើក ព្រមទាំងបានអញ្ជើញជាគណៈអធិបតី ក្នុងពិធីសម្ពោធសមិទ្ធផលនានា និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗ ចំនួន៨៣លើក។

**៣.៣-កិច្ចសហប្រតិបត្តិការអន្តរជាតិ**

ការងារសហប្រតិបត្តិការអន្តរជាតិរបស់ព្រឹទ្ធសភា ជាពិសេស ទំនាក់ទំនងក្នុងកម្រិតតំបន់ និងអន្តរជាតិ សមាជិក សមាជិកាព្រឹទ្ធសភា បានចូលរួមយ៉ាងសកម្ម និងទទួលបានលទ្ធផលជាវិជ្ជមានដូចខាងក្រោមៈ

-បានអនុញ្ញាតឱ្យថ្នាក់ដឹកនាំនៃក្រុមហ៊ុនផារ៉ាហ្គន និងក្រុមប្រឹក្សាភិបាលសាកលវិទ្យាល័យអន្តរជាតិផារ៉ាហ្គន PARAGON International University ដឹកនាំដោយលោក**ដាមៀរ មូរសែវ** Mr. Damir Musaev នាយកប្រតិបត្តិក្រុមហ៊ុនផារ៉ាហ្គន ចូលជួបសម្ដែងការគួរសម និងពិភាក្សា

ការងារនៅវិមានព្រឹទ្ធសភា

-បានអនុញ្ញាតឱ្យលោក Raphaël FERRY អ្នកសារព័ត៌មាន Le Petit journal ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបធ្វើបទសម្ភាសន៍អំពីប្រវត្តិការងាររបស់លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី ប៉ូស៊ី** ប្រធានគណៈកម្មការទី៥ ចាប់តាំងពីមុនរបបសម័យខ្មែរក្រហម រហូតមកដល់ពេលបច្ចុប្បន្ន នៅវិមានព្រឹទ្ធសភា

-បានអនុញ្ញាតឱ្យMr.Gyuhwa JANG (T&C Korea), Dr.Younsoo PARK (Korea Importers Association), Mr.Micheal LIM (CEO of SandwellPetrogas Ltd.) និងMr. Khath Chen (Cambodian Embassy in Seoul Korea) ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអាហារសាមគ្គីក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកសហប្រតិបត្តិការជាមួយអន្តរសភាកម្ពុជា ឡាវ វៀតណាម ក្រោមអធិបតីភាពលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកសហប្រតិបត្តិការជាមួយអន្តរសភាកម្ពុជា-ឡាវ-វៀតណាម នៅភោជនីយដ្ឋាន ឡុង កី រាជធានីភ្នំពេញ។

ថ្ងៃ ច័ន្ទ ១១ កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០២៤

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**កិត្តិសង្គហបណ្ឌិត ទេព ងន**

<u>ចម្លងជូន</u>

- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
  (ជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ